multicultural
MENTAL HEALTH AUSTRALIA

Khmer

ឯកសារព័ត៌មាន

# បញ្ហាចិត្តរោគ និងគ្រឿងញៀន ព្រមទាំងសុរា
## (Psychosis and drug and alcohol issues)

ចិត្តរោគផ្លាស់ប្តូរនូវរបៀបដែលបុគ្គលនោះគិត, មានអារម្មណ៍ និងបញ្ចេញអាកប្បកិរិយា។ នេះអាចបណ្តាលឲ្យមានបញ្ហានៅក្នុងក្រុមគ្រួសារ និងជីវិតក្នុងសង្គមរបស់ពួកគេ ក៏ដូចជាបញ្ហានៅឯសាលារៀន ឬនៅកន្លែងធ្វើការ។ ចិត្តរោគអាចបណ្តាលឲ្យមានការប្រើគ្រឿងញៀន ឬការធ្លាក់ទឹកចិត្ត ឬក៏មានការប្រឈមមុខកាន់តែខ្លាំងឡើងនឹងការធ្វើទុក្ខទោសដល់ខ្លួនឯង ឬការប៉ុនប៉ងធ្វើអត្តឃាត។ ឯកសារព័ត៌មាននេះ ផ្តល់ព័ត៌មានអំពីការកើតមានជំងឺផ្លូវចិត្តជាបន្តបន្ទាប់ និងបញ្ហាសុខភាពផ្លូវចិត្តដ៏ស្មុគស្មាញនានា ដូចជាចិត្តរោគដែលបណ្តាលមកពីការសេពគ្រឿងញៀន ឬសុរា និងស្ថានភាពចិត្តរោគគួបនឹងការសេពគ្រឿងញៀន ឬសុរាហើយនិងការព្យាបាល ក៏ដូចជាជំនួយដែលមានជូន។

## អ្វីទៅជាចិត្តរោគ?

ចិត្តរោគបង្ហាញលក្ខណៈតាមរយៈបណ្តុំនៃអាការៈរោគជាក់លាក់មួយចំនួន។ បុគ្គលណាម្នាក់ដែលកើតមានជំងឺផ្លូវចិត្ត មានការយល់ខុសបែកឆ្វេងខ្លាំងអំពីភាពពិតជាក់ស្តែង ហើយអាចបង្ហាញឲ្យឃើញជាការផ្លាស់ប្តូរអត្តចរិត។ មនុស្សផងទាំងពួងដែលមានអាការៈរោគនៃជំងឺផ្លូវចិត្តបែបនេះ មិនដឹងខ្លួនឯងថាកើតមានចិត្តរោគឡើយ ដោយសារគេបាត់បង់នូវអ្វីដែលជាភាពពិតជាក់ស្តែង។

## តើអាការៈរោគមានអ្វីខ្លះ?

មនុស្សយើងមានបទពិសោធន៍អំពីចិត្តរោគនៅក្នុងលក្ខណៈខុសៗគ្នា ដោយសារអាការៈរោគមានលក្ខណៈខុសគ្នាពីម្នាក់ទៅមនុស្សម្នាក់ទៀត។ រោគសញ្ញាដើមដំបូងនៃចិត្តរោគមានរួមទាំង៖

- ការផ្លាស់ប្តូរទម្លាប់នៃដំណេក។
- ការផ្លាស់ប្តូរចំណង់ទទួលទានអាហារ។
- ការដកខ្លួនចេញពីសង្គម។
- ការថែទាំខ្លួន និងអនាម័យផ្ទាល់ខ្លួនថយចុះ។
- ការនិយាយស្តីមិនសមហេតុផល។
- ការងប់ចិត្តនឹងសកម្មភាព ឬគំនិតផ្សេងៗណាមួយ។

ជាទូទៅបុគ្គលដែលមានអាការៈរោគនៃចិត្ត នឹងមានបញ្ហាជាច្រើនដូចជាបញ្ហាផ្ទាល់ខ្លួន បញ្ហាសង្គម និងបញ្ហាការងារចិញ្ចឹមជីវិត។

អាការៈរោគខ្លាំងៗជាងនេះទៀតមានរួមទាំង៖

**ភាពវើវាយស្រមើស្រមៃ** - ការឃើញ, ការឮ, ការមានអារម្មណ៍, ការដឹងរសជាតិ ឬក៏ធុំក្លិនអ្វីមួយដែលមិនបានកើតឡើង។ ឧទាហរណ៍ បុគ្គលនោះអាច ¡¡ãឮសំឡេងផ្សេងៗនៅក្នុងខួរក្បាល¡¡À ឬក៏មើលឃើញ ឬក៏មានអារម្មណ៍ថាប៉ះនឹងអ្វីដែលមិនមានកើតឡើង ដូចជាមានអារម្មណ៍ថា ¡¡ãសត្វអ្វីមួយកំពុងតែវារនៅក្នុងសាច់របស់គាត់¡¡À ជាដើម។ ការវើវាយស្រមើស្រមៃទាំងនេះ ធ្វើឲ្យតានតឹងចិត្ត ហើយអាចបណ្តាលឲ្យជនដែលមានបទពិសោធន៍យ៉ាងនេះ មានលក្ខណៈកាចច្រងេងច្រងាង និងពិបាកក្នុងការនិយាយជាមួយ។

**ភាពវង្វេងនាំឲ្យគិតថាមានភាពអស្ចារ្យ** - ឧទាហរណ៍ បុគ្គលណាម្នាក់អាចគិតថា គាត់ជាមនុស្សល្បីល្បាញ ដូចជាតារាភាពយន្ត ឬមេដឹកនាំសាសនាជាដើម។ ពួកគាត់អាចគិតថា ចម្រៀងមួយចំនួនអាចមានអត្ថន័យសម្ងាត់សម្រាប់តែពួកគាត់ ឬក៏គាត់មានអារម្មណ៍ថា គាត់មានមហិទ្ធានុភាពពិសេស។

**ភាពវង្វេងនាំឲ្យមានការភ័យខ្លាចដោយគ្មានហេតុផល** - ឧទាហរណ៍ បុគ្គលណាម្នាក់អាចគិតថា ខ្លួនគាត់មានគេតាមដានពីក្រោយ, រៀបចំផែនការប្រឆាំងនឹងខ្លួន ឬគិតថា មានឥទ្ធិពលណាមួយ ឬជនណាម្នាក់កំពុងគ្រប់គ្រងគាត់។ ពួកគាត់អាចមានជំនឿថា ខ្លួនកំពុងរងការឃាយី ឬក៏មានការមន្ទិលសង្ស័យទៅលើអ្វីមួយដោយពុំមានមូលហេតុច្បាស់លាស់។

**វាចា ឬអត្តចរិតពាសវាលពាសកាល** - ឧទាហរណ៍ បុគ្គលណាម្នាក់អាចនិយាយ ឬប្តូរប្រធានបទលឿនរហ័សខ្លាំងពេកពីប្រធានបទមួយទៅប្រធានបទមួយទៀត ឬក៏គាត់អាចមានបញ្ហាបញ្ចេញនូវគំនិតរបស់គាត់។ ពួកគាត់អាចមានការលំបាកនៅក្នុងការធ្វើសកម្មភាពប្រចាំថ្ងៃ ដូចជាការចម្អិនអាហារ ឬការបោកគក់ ឬគាត់អាចមានប្រតិកម្មដោយមិនសមរម្យទៅលើស្ថានភាពណាមួយ។

**បន្លាស់ប្តូរអារម្មណ៍** - ឧទាហរណ៍ បុគ្គលណាម្នាក់អាចបង្ហាញឲ្យឃើញនូវអារម្មណ៍តិចតួច ឬមិនសូវនិយាយស្តី។ ពួកគាត់អាចដកខ្លួនចេញពីអ្នកដទៃ ឬមានបញ្ហាក្នុងការគិត។

**ការថប់បារម្ភក្នុងចិត្ត** - ឧទាហរណ៍ បុគ្គលណាម្នាក់អាចមានអារម្មណ៍តានតឹងចិត្ត ឬភ័យព្រួយយ៉ាងខ្លាំង ហើយមិនអាចសម្រួលចិត្តឲ្យស្ងប់បាន។

អាការៈរោគទាំងនេះ អាចកើតឡើងរយៈពេលពីរបីម៉ោង ឬពីរបីថ្ងៃប៉ុណ្ណោះ ប៉ុន្តែក៏អាចបន្តអស់ពេលច្រើនអាទិត្យ ច្រើនខែដែរ ហើយមានពេលខ្លះច្រើនឆ្នាំទៀតផង ប្រសិនបើជននោះមិនបានទទួលការព្យាបាលឲ្យបានត្រឹមត្រូវទេនោះ។

For more information about Multicultural Mental Health Australia
visit www.mmha.org.au
Multicultural Mental Health Australia,
Locked Bag 7118, Parramatta CBD, NSW, 2124
Phone: 02 9840 3333 Fax: 02 9840 3388 Email: admin@mmha.org.au



## តើនរណាខ្លះដែលកើតមានចិត្តរោគ?

ក្នុងចំណោមពលរដ្ឋដែលមានជំងឺផ្លូវចិត្តគឺមានប្រហែលជា២% ប៉ុណ្ណោះដែលមានជំងឺផ្លូវចិត្តក្នុងស្ថានភាពធ្ងន់ធ្ងរ ដែលអាចបណ្ដាលឲ្យមានរោគសញ្ញានៃចិត្តរោគ។ ចិត្តរោគជាជំងឺដែលគេអាចព្យាបាលបាន។ ជនគ្រប់រូបអាចកើតចិត្តរោគបាន ហើយវាកើតមាននៅក្នុងសង្គមគ្រប់វប្បធម៌ទាំងអស់។ ជាធម្មតាជំងឺនេះកើតឡើងជាលើកដំបូងនៅក្នុងចន្លោះអាយុពី១៥ ទៅ៣០ឆ្នាំ។

## តើចិត្តរោគបណ្ដាលមកពីមូលហេតុអ្វីខ្លះ?

គេមិនទាន់ដឹងច្បាស់ពេញលេញអំពីមូលហេតុទាំងឡាយដែលបណ្ដាលឲ្យកើតចិត្តរោគនៅឡើយទេ ប៉ុន្តែជំងឺនេះបណ្ដាលមកពីកត្តាមួយចំនួន ឧទាហរណ៍៖

- ការមានគ្រោះថ្នាក់របួសខួរក្បាល។
- ការមានភាពតានតឹងផ្លូវចិត្ត ឧទាហរណ៍ដូចជាការបាត់បង់ជនជាទីស្រឡាញ់ ឬធ្លាប់ឆ្លងកាត់សង្គ្រាម ឬការធ្វើទារុណកម្ម, ការធ្វើអន្តោប្រវេសន៍ចាកស្រុកទៅប្រទេសថ្មី, មានស្ថានភាពរស់នៅដែលធ្វើឲ្យតានតឹងចិត្ត, ការចាប់ផ្ដើមចូលរៀនសាលា, មាតាបិតាលែងលះគ្នា, ការបែកបាក់សម្ព័ន្ធមេត្រី ឬក៏ការប្រឡងនៅសកលវិទ្យាល័យជាដើម។
- ការប្រើប្រាស់គ្រឿងញៀន និងសុរាមិនត្រឹមត្រូវ។
- ការមានចិត្តរោគនៅក្នុងប្រវត្តិក្រុមគ្រួសារ អាចបង្កើនគ្រោះថ្នាក់នៃការប្រឈមមុខនឹងចិត្តរោគ។

បុគ្គលណាម្នាក់ដែលកើតចិត្តរោគ ហើយប្រើគ្រឿងញៀនផងនោះ នឹងធ្វើឲ្យគេកាន់តែប្រឈមមុខនឹងគ្រោះថ្នាក់កាន់តែខ្លាំងនឹងការមានជំងឺផ្លូវចិត្តម្ដងទៀត ហើយគេអាចមានបញ្ហាធ្លាក់ទឹកចិត្ត, ការថប់បារម្ភ ឬក៏មានបញ្ហាចងចាំ។ គេអាចត្រូវការពេលយូរជាងនេះទៀតដើម្បីជាធូរស្បើយ ហើយក៏មានអាការៈចិត្តរោគកាន់តែធ្ងន់ជាងមុនទៀតផង។

## តើចិត្តរោគបណ្ដាលមកពីគ្រឿងញៀនជាអ្វី?

ចិត្តរោគបណ្ដាលមកពីគ្រឿងញៀនអាចកើតឡើងបាននៅពេលដែលបុគ្គលណាម្នាក់ដែលងាយរងគ្រោះដោយសារការកើតចិត្តរោគទៅប្រើគ្រឿងញៀនដូចជាកញ្ឆា, អាំហ្វេតាមីន (speed) និងកាកូអ៊ីន។ ជាធម្មតារោគសញ្ញានៃចិត្តរោគបណ្ដាលមកពីគ្រឿងញៀន កើតឡើងឆាប់រហ័ស ហើយមានរយៈពេលខ្លី (ចន្លោះពីពីរបីម៉ោង ទៅពីរបីថ្ងៃ) រហូតទាល់តែអស់ឥទ្ធិពលនៃគ្រឿងញៀន។ អាការៈរោគទូទៅបំផុតដែលទាក់ទងនឹងចិត្តរោគបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន មានដូចជាការមានបញ្ហាចងចាំ, ការភ័ន្តវង្វេង និងការស្រមើស្រមៃរវើរវាយ។ ការព្យាបាលមានប្រសិទ្ធភាពល្អចំពោះរោគសញ្ញាទាំងនេះ។

### តើអ្វីទៅជាស្ថានភាពជំងឺផ្លូវចិត្តគួបនឹងការសេពគ្រឿងញៀនឬសុរា ?

ស្ថានភាពជំងឺផ្លូវចិត្តគួបនឹងការសេពគ្រឿងញៀន ឬសុរា គឺកើតឡើងនៅពេលបុគ្គលណាម្នាក់មានជំងឺផ្លូវចិត្ត - ឧទាហរណ៍ដូចជាជំងឺផ្លូវចិត្តដែលធ្វើឱ្យភ័ន្តវង្វេង (Schizophrenia), ការធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ, វិបល្លាសផ្លូវចិត្តដែលមានការផ្លាស់ប្ដូរអារម្មណ៍ពីសប្បាយទៅជាទុក្ខឆាប់រហ័ស(bipolar) ឬក៏វិបល្លាសផ្លូវចិត្តទាក់ទងនឹងអត្តចរិត - និងបញ្ហានៃការសេពសុរា ឬគ្រឿងញៀន។

ការមានជំងឺផ្លូវចិត្ត បង្កើនកាន់តែខ្លាំងឡើងនូវគ្រោះថ្នាក់នៃការប្រើប្រាស់សុរា និងគ្រឿងញៀនខុសបែបបទ។ បណ្ដាជនដែលមានជំងឺផ្លូវចិត្ត អាចប្រើសុរា ឬគ្រឿងញៀនដើម្បីធ្វើឲ្យគេមានអារម្មណ៍ល្អ, បញ្ឈប់អារម្មណ៍ឯកោ, បន្ធូរអារម្មណ៍, ដើម្បីការសប្បាយ, ទប់ទល់នឹងភាពតានតឹងផ្លូវចិត្ត ឬដើម្បីចូលរួមនៅជាមួយក្រុមណាមួយក្នុងសង្គម។

នៅគ្រាដំបូង គ្រឿងញៀន ឬសុរាអាចជួយបុគ្គលនោះឲ្យមានអារម្មណ៍ល្អជាងមុន ឬជួយសម្រួលដល់អាការៈរោគរបស់គេ ប៉ុន្តែនៅពេលដែលអស់ឥទ្ធិពលគ្រឿងញៀន ឬសុរា អាការៈរោគទាំងនោះកាន់តែមានសភាពធ្ងន់ធ្ងរជាងមុន។ ការធ្វើឲ្យជាធូរស្បើយពីជំងឺផ្លូវចិត្ត មានការលំបាកខ្លាំងជាងសម្រាប់ជនដែលមានជំងឺផ្លូវចិត្តគួបនឹងការសេពគ្រឿងញៀន ឬសុរា។

នៅពេលដែលបុគ្គលណាម្នាក់មានជំងឺផ្លូវចិត្តទៅសេពគ្រឿងញៀន ឬសុរា វាអាចបណ្ដាលឲ្យមានបញ្ហាជាច្រើននៅគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់គេ ដូចជាការរៀនសូត្រ, ការងារ, ការប្រាស្រ័យទាក់ទងនឹងជនដទៃ, ការស្នាក់នៅ, លុយកាក់ និងច្បាប់ ហើយមិនតែប៉ុណ្ណោះពួកគេអាចប្រឈមមុខកាន់តែខ្លាំងទៅនឹងការធ្វើឲ្យខ្លួនឯងកាន់តែមានទុក្ខ ឬក៏ប៉ុនប៉ងធ្វើអត្តឃាត។

ការពិនិត្យតាមដានជំងឺផ្លូវចិត្តនៃជនណាម្នាក់ដែលមានបញ្ហាសុរា ឬគ្រឿងញៀន គឺត្រូវចំណាយពេលយូរជាងធម្មតា។

## តើខ្ញុំអាចជួយជនណាម្នាក់ដែលមានចិត្តរោគ ឬស្ថានភាពជំងឺផ្លូវចិត្តនឹងការសេពគ្រឿងញៀន ឬសុរា យ៉ាងដូចម្ដេចទៅ?

វប្បធម៌ដើរតួនាទីយ៉ាងចម្បងមួយនៅក្នុងការយល់ដឹងរបស់បណ្ដាជនអំពីជំងឺផ្លូវចិត្ត ឧទាហរណ៍ នៅក្នុងវប្បធម៌ខ្លះអត្តចរិតនៃជំងឺផ្លូវចិត្តអាចត្រូវគេមើលឃើញថាបានបណ្ដាលមកពីមហិទ្ធិឫទ្ធិមន្តអាគមន៍ហួសពីធម្មជាតិទៅវិញ។ ការបញ្ចៀសនូវភាពអាម៉ាស់ ឬដកចេញនូវឧបសគ្គនានាដែលបញ្ឈប់បណ្ដាជនមិនឲ្យស្វែងរកជំនួយ គឺជារឿងសំខាន់។

ក្រុមគ្រួសារ និងញាតិមិត្តនៃជនដែលមានកើតរោគចិត្ត អាចមិនដឹងថាត្រូវធ្វើយ៉ាងណា ហើយអាចមានការលំបាកនៅក្នុងការចាត់វិធានការដំបូង ដើម្បីជួយជននោះ។ បញ្ហានេះអាចនាំមកនូវការបារម្ភតានតឹងចិត្ត ខ្លាំង ហើយពួកគេអាចមានអារម្មណ៍ថានេះជាកំហុសរបស់គេ ឬក៏វង្វេងវង្វាន់ញាប់ញ័រ, ភាន់ភាំង មិនដឹងធ្វើយ៉ាងដូចម្ដេច។ មានពេលខ្លះ ជនដែលមានរោគចិត្តនេះមិនដឹងខ្លួនថា គេត្រូវការជំនួយទៀតផង ឬក៏គេអាចមានអារម្មណ៍ខ្មាស់អៀន ឬភ័យខ្លាចដោយសារតែភាពអាម៉ាស់ក្នុងសង្គមទាក់ទងនឹងការមានជំងឺផ្លូវចិត្ត។ វាជាការសំខាន់ ដែលជនជាទីស្រឡាញ់របស់អ្នកទទួលនូវជំនួយឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន។

For more information about Multicultural Mental Health Australia
visit www.mmha.org.au

Multicultural Mental Health Australia,
Locked Bag 7118, Parramatta CBD, NSW, 2124
Phone: 02 9840 3333 Fax: 02 9840 3388 Email: admin@mmha.org.au

ក្រុមគ្រួសារ និងញាតិមិត្តអាចជួយបានតាមរយៈការប្រាប់ដល់ជនមានជំងឺនោះយ៉ាងស្ងៀមស្ងាត់ និងច្បាស់លាស់ថា អ្វីដែលពួកគេកត់សម្គាល់ឃើញកន្លងទៅនេះ ធ្វើឲ្យពួកគេមានកង្វល់។ ត្រូវប្រាប់ពួកគេថា អ្វីៗអាចមានការប្រសើរឡើង ហើយការស្នើសុំជំនួយគឺជាសញ្ញាមួយនៃសេចក្តីក្លាហាន មិនមែនជាចំណុចខ្សោយនោះ ទេ។ ត្រូវបាប្រ់គេថា គេអាចរកជំនួយបានតាមរយៈគ្រូពេទ្យទូទៅ (GP) និងពីសេវាផ្នែកសុខភាពផ្លូវចិត្តផ្សេងៗទៀត។ ការផ្តល់នូវក្តីសង្ឃឹមជាប់ជានិច្ច ហើយត្រូវអត់ធ្មត់ និងការលើកទឹកចិត្តគឺជារឿងសំខាន់។ ជំងឺផ្លូវចិត្តជាជំងឺដែលគេអាចព្យាបាលបាន។

## តើអ្វីទៅជាការព្យាបាលចិត្តរោគ និង ស្ថានភាពជំងឺផ្លូវចិត្តគួបនឹងការសេពសុរា ឬគ្រឿងញៀន?

ជនដែលកំពុងមានអាការៈរោគចិត្ត ឬជនដែលកំពុងមានស្ថានភាពជំងឺផ្លូវចិត្តគួបនឹងការសេពសុរា ឬគ្រឿងញៀន មិនត្រូវព្យាយាមដោះស្រាយបញ្ហានេះតែម្នាក់ឯងនោះទេ។ ចិត្តរោគអាចត្រូវគេព្យាបាលដោយជោគជ័យ ហើយមនុស្សភាគច្រើនដែលមានជំងឺនេះមានការជាសះស្បើយល្អប្រសើរ។ មានអ្នកខ្លះជាសះស្បើយលឿនរហ័ស ហើយត្រូវការជំនួយតិចតួច។ រីឯអ្នកខ្លះទៀតអាចត្រូវការពេលយូរ និងត្រូវការជំនួយយ៉ាងពេញទំហឹងជាងនេះដើម្បីឱ្យជាសះស្បើយ។

ជម្រើសនៃការព្យាបាលគឺមានច្រើន ដូចជាការប្រើថ្នាំពេទ្យ, ការមើលថែទាំជាបន្តបន្ទាប់ពីគ្រូពេទ្យជំងឺផ្លូវចិត្ត, ការជួយជ្រោមជ្រែងខាងផ្នែកផ្លូវចិត្ត និងសង្គម និងពីក្រុមគាំទ្រលើកទឹកចិត្ត។ មានពេលខ្លះ ជនមួយចំនួនអាចត្រូវចូលស្នាក់នៅក្នុងមន្ទីរពេទ្យ។

ស្ថានភាពជំងឺផ្លូវចិត្តគួបនឹងការសេពគ្រឿងញៀនឬសុរា គឺជាស្ថានភាពជំងឺមួយដែលត្រូវការជំនួយគាំពារ ពីខាងផ្នែកវេជ្ជសាស្ត្រ។ គេមានថ្នាំពេទ្យជាច្រើនសម្រាប់ព្យាបាលជួយសម្រាលដល់អាការៈរោគ និងទប់ស្កាត់មិនឲ្យជំងឺរើឡើងវិញ។ ការទទួលនូវការព្យាបាលឲ្យបានកាន់តែឆាប់ដែលអាចធ្វើទៅបាន អាចជួយយ៉ាងច្រើនដល់ការធ្វើឲ្យអ្នកមានជំងឺផ្លូវចិត្តគួបនឹងការសេពគ្រឿងញៀន ឬសុរាជាធូរស្បើយឡើងវិញ និងកាត់បន្ថយឱកាសនៃការរើឡើងវិញនៃជំងឺរបស់ពួកគេ។

## តើខ្ញុំត្រូវធ្វើអ្វីខ្លះ នៅពេលជួបប្រទះនឹងចិត្តរោគ ឬស្ថានភាពជំងឺផ្លូវចិត្តគួបនឹងការសេពសុរា ឬគ្រឿងញៀន?

- ទៅជួបគ្រូពេទ្យទូទៅ (GP) គឺជាជំហានដំបូង។
- រកព័ត៌មានឲ្យបានច្រើនបំផុតដែលអាចធ្វើបានអំពីជំងឺ ដើម្បីជួយអ្នក និងក្រុមគ្រួសារអ្នកយល់ដឹងនូវអ្វីដែលកំពុងតែកើតឡើង អ្វីដែលត្រូវរំពឹងទុក និងរបៀបដែលត្រូវចាត់ចែងស្ថានភាពចិត្តរោគ។ រកឲ្យដឹងថា តើមានសេវាសុខភាពផ្លូវចិត្តណាខ្លះដែលមានជូន ហើយត្រូវស្វែងរកការព្យាបាល និងជំនួយ។
- ទាក់ទងទៅសេវាសុខភាពផ្លូវចិត្តនៅក្នុងតំបន់ ឬសេវាអំពីគ្រឿងញៀន និងសុរា ដើម្បីរកព័ត៌មានបន្ថែមអំពីជំនួយផ្សេងៗដែលមានជូន។
- ស្វែងរកការពិគ្រោះប្រឹក្សាយោបល់។ ការមានជនណាម្នាក់និយាយជាមួយ គឺជាផ្នែកមួយយ៉ាងសំខាន់នៃការព្យាបាល។ ការប្រឹក្សាយោបល់សម្រាប់ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកក៏មានប្រយោជន៍ដែរ។
- ការចាត់ចែងគ្រប់គ្រងភាពតានតឹងផ្លូវចិត្ត។ ឥទ្ធិពលអវិជ្ជមាននៃការតានតឹងចិត្ត អាចរួមទាំង ការអស់កម្លាំង, ការម៉ូម៉ៅរសាប់រសល់, ការថប់បារម្ភ, ការប្រែប្រួលនៃចំណង់អាហារ និងការទទួលទានដំណេកមិនស្កបបាន។ វិធីផ្សេងៗក្នុងការជួយកាត់បន្ថយភាពតានតឹងផ្លូវចិត្តរួមទាំង ការបន្ធូរអារម្មណ៍, ការដកដង្ហើមវែង, ការរៀបចំខ្លួនឲ្យបានត្រឹមត្រូវល្អ, ការចាត់ចែងពេលឲ្យមានប្រសិទ្ធភាព និងការកាត់បន្ថយការទទួលខុសត្រូវ និងកាតព្វកិច្ចផ្សេងៗឲ្យនៅតិចជាងមុន។
- ត្រូវរក្សាសុខភាពឲ្យបានល្អ។ ត្រូវទទួលទានដំណេក និងអាហារឲ្យបានល្អ ធ្វើលំហាត់ប្រាណទៀងទាត់ និងត្រូវទៅជួបពេទ្យដើម្បីពិនិត្យតាមដានជំងឺឲ្យបានទៀងទាត់។
- ដាក់គោលដៅសមរម្យដែលអាចធ្វើបាន ហើយអបអរចំពោះជោគជ័យទាំងនោះ។
- មជ្ឈដ្ឋានដែលពោរពេញទៅដោយការជួយទ្រទ្រង់ អាចជួយកាត់បន្ថយភាពឯកោ និងជួយឲ្យអ្នកដោះស្រាយនឹងរោគសញ្ញានៃចិត្តរោគ។ ការមានក្រុមគ្រួសារ មិត្តភក្តិ និងក្រុមផ្សេងៗដែលមានការគាំទ្រ ជួយអ្នកឲ្យរក្សាចិត្តជាវិជ្ជមានអំពីការជាធូរស្បើយឡើងវិញ ដើម្បីបង្កើតបានជាមជ្ឈដ្ឋាននឹងនដែលមានការស្រឡាញ់រាប់អាន និងដើម្បីស្តាបនាភាពជឿជាក់លើសមត្ថភាពខ្លួនឯង ការស្តាបនា និងការរក្សាទំនាក់ទំនងក្នុងសង្គមឲ្យបានល្អ គឺជាការសំខាន់ ហើយប្រសិនបើសម្ព័ន្ធមេត្រីភាពមានបញ្ហា ត្រូវតាមរកវិធីប្រឹក្សាយោបល់ និងរិះរកវិធីដោះស្រាយបញ្ហាទាំងនោះ។
- ត្រូវទប់ស្កាត់មិនឲ្យជំងឺរើឡើងវិញ។ រកឲ្យដឹងនូវមូលហេតុផ្សេងៗដែលបណ្តាលឲ្យមានភាពតានតឹងចិត្ត, សរសេរទុកនូវសញ្ញាដំបូងនៃការរើឡើងវិញនៃជំងឺ, រកឲ្យដឹងនូវវិធីសាស្ត្រដែលអាចទប់ទល់បាន, រាយបញ្ជីថ្នាំដែលអ្នកគួរលេប ដើម្បីគ្រប់គ្រងនូវសញ្ញាដំបូងទាំងឡាយ និងរកឲ្យដឹងថា តើត្រូវទាក់ទងទៅខាងណាខ្លះ ដើម្បីសុំជំនួយ និងការគាំទ្របន្ថែមទៀត។

ដោយសារវិធីសាស្ត្រនីមួយៗមានប្រសិទ្ធភាពល្អប្រសើរសម្រាប់មនុស្សខុសៗគ្នា សូមព្យាយាមសាកល្បងនូវវិធីសាស្ត្រផ្សេងៗគ្នាទាំងនោះ ដើម្បីឲ្យដឹងថា តើវិធីសាស្ត្រមួយណាមានប្រសិទ្ធភាពសម្រាប់អ្នក។ មនុស្សខ្លះ ជាសះស្បើយលឿនរហ័ស ដោយមានការគាំពារតិចតួច ចំណែកឯអ្នកខ្លះទៀតអាចមានការប្រសើរឡើងបាននៅពេលមានការជួយទ្រទ្រង់អស់ពេលយូរជាងនេះ។

## ក្នុងនាមជាមិត្តភក្តិ និងសមាជិកគ្រួសារម្នាក់នោះ តើខ្ញុំគ្រប់គ្រងចាត់ចែងចិត្តរោគ ឬស្ថានភាពជំងឺផ្លូវចិត្តគួបនឹងការសេពសុរា ឬគ្រឿងញៀនយ៉ាងដូចម្តេចទៅ?

អាការៈចិត្តរោគ គឺធ្វើឲ្យជនគ្រប់ៗគ្នាមានភាពតានតឹងចិត្ត។ ក្នុងនាមជាសមាជិកគ្រួសារ ឬមិត្តភក្តិ អ្នកអាចមានអារម្មណ៍ភ័យខ្លាច, ក្រៀមក្រំទុក្ខព្រួយ, ខឹងសម្បា, តប់ប្រមល់, ខ្មាស់អៀន និងអស់សង្ឃឹម។ ការព្យាបាលចិត្តរោគ មានពេលខ្លះអាចត្រូវការពេលយូរ ដូច្នេះត្រូវត្រៀមខ្លួនទុកជាមុនអំពីបញ្ហាជាច្រើនដែលត្រូវប្រឈមមុខ។

មិនត្រូវប្រឈមមុខនឹងបញ្ហាទាំងនោះតែម្នាក់នោះទេ។ និយាយពិភាក្សាជាមួយនឹងជនដទៃទៀត - មិត្តភក្តិ, សមាជិកគ្រួសារ, អ្នកជំនាញខាងព្យាបាលជំងឺ - ដោយសារពួកគេអាចជួយអ្នក និងផ្តល់ការគាំទ្រ ហើយត្រូវចងចាំថា អ្នកត្រូវការពេលសម្រាប់ខ្លួនអ្នក។ អ្នកអាចត្រូវមានការប្រុងប្រយ័ត្នដើម្បីៈ

- ចៀសវៀងអំពើហិង្សា និងធានាឲ្យបានថាអ្នកមានសុវត្ថិភាព។ មិនត្រូវស្ទាក់ស្ទើរចិត្តក្នុងការហៅរកជំនួយឡើយ ប្រសិនបើអ្នករងការគំរាមកំហែង ឬធ្វើទុក្ខបុកម្នេញពីសកម្មភាពរបស់ជនណាម្នាក់។ ទូរស័ព្ទទៅប៉ូលិសប្រសិនបើចាំបាច់។
- បង្កើតវិធីសាស្ត្រនានា ដែលជួយដល់ជននោះដោយមិនត្រូវទ្រទ្រង់ការញៀនគ្រឿងញៀន ឬសុរានោះឡើយ។ ឧទាហរណ៍ ទិញអាហារឲ្យពួកគេ ឬបង់ថ្លៃឈ្នួលទឹកភ្លើងជំនួសវិញ ជាជាងឲ្យលុយពួកគេ។

For more information about Multicultural Mental Health Australia
visit www.mmha.org.au

Multicultural Mental Health Australia,
Locked Bag 7118, Parramatta CBD, NSW, 2124
Phone: 02 9840 3333 Fax: 02 9840 3388 Email: admin@mmha.org.au

multicultural
MENTAL HEALTH AUSTRALIA

- អត្តឃាត និងការគំរាមធ្វើអត្តឃាត គឺជាផ្នែកមួយនៃអត្តចរិតរបស់ជនដែលមានជំងឺផ្លូវចិត្តគួបនឹងការសេពគ្រឿងញៀន ឬសុរា។ ក្រុមគ្រួសារ និងមិត្តភក្តិត្រូវតែរកវិធី ដើម្បីឆ្លើយតប និងដោះស្រាយចំពោះបញ្ហានេះ។
- នៅពេលជំងឺរើឡើងវិញ មិនត្រូវមានការភ័យខ្លាចក្នុងការស្វែងសុំជំនួយឡើយ ហើយត្រូវផ្តល់ការជួយទ្រទ្រង់ដែលនាំមកនូវអំណោយផលដល់ជននោះ។
- បង្ហាញឲ្យឃើញថា អ្នកយល់អំពីការគិតរបស់ជននោះអំពីបញ្ហា និងជម្រើសផ្សេងៗ ក៏ដូចជាជីវិតរស់នៅរបស់គេ។
- ប្រាប់គេឲ្យដឹងនូវអត្តចរិតណាមួយដែលអ្នកអាចទទួលយកបាន។ ត្រូវរក្សាការប្រាស្រ័យទាក់ទងដោយភាពស្ងៀមស្ងាត់ និងច្បាស់លាស់។
- ត្រូវរក្សាទម្លាប់ធម្មតា និងការអបអរពិធីបុណ្យផ្សេងៗដូចជាបុណ្យកំណើត, បុណ្យសាសនា ឬវប្បធម៌ និងជាពិសេសសកម្មភាពរបស់ក្រុមគ្រួសារ។

## ត្រូវការព័ត៌មានបន្ថែមទេ?

**ខាងផ្នែកអ្នកបកប្រែភាសា**
**សេវាបកប្រែភាសា (TIS)**
ទូរស័ព្ទ៖ 13 14 50

**សេវាសុខភាពផ្លូវចិត្ត និងលេខទូរស័ព្ទគ្រាអាសន្ន២៤ ម៉ោង** មាននៅក្នុងសៀវភៅបញ្ជីលេខទូរស័ព្ទក្នុងតំបន់លោកអ្នក។

**Lifeline សេវាប្រឹក្សាយោបល់តាមទូរស័ព្ទ២៤ម៉ោង**
សេវាប្រឹក្សាយោបល់ និងព័ត៌មានផ្តល់ជូនដោយអង្គការក្រៅរដ្ឋាភិបាល។
ទូរស័ព្ទ៖ 13 11 14
វ៉ិបសាយថ៍៖ www.lifeline.org.au

**បណ្តាញព័ត៌មានអូស្ត្រាលីអំពីគ្រឿងញៀន (ADIN)**
ព័ត៌មានអំពីសេវាគ្រឿងញៀន និងសុរា នៅក្នុងរដ្ឋ និងដែនដីនីមួយៗរបស់អូស្ត្រាលី។
វ៉ិបសាយថ៍៖ www.adin.com.au

**Carers Australia**
អង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ជូនអ្នកថែទាំមនុស្សនូវព័ត៌មាន, ការបញ្ជូន និងឯកសារសម្ភារៈអប់រំផ្សេងៗ។
ទូរស័ព្ទ៖ 1800 242 636
វ៉ិបសាយថ៍៖ www.carersaustralia.com.au

**សូមបញ្ចូលព័ត៌មានទាក់ទងក្នុងតំបន់នៅកន្លែងនេះ**

..............................................................................

..............................................................................

..............................................................................

**សុខភាពផ្លូវចិត្តពហុវប្បធម៌របស់អូស្ត្រាលី (MMHA)**
ទូរស័ព្ទ៖ 02 9840 3333
ទូរសារ៖ 02 9840 3388
វ៉ិបសាយថ៍៖ www.mmha.org.au
អ៊ីមែល៖ Email: admin@mmha.org.au

**Sane Australia**
គឺជាអង្គការសប្បុរសធម៌ថ្នាក់ជាតិខាងសុខភាពផ្លូវចិត្ត ដែលផ្តល់ព័ត៌មាន និងការបញ្ជូន តាមរយៈខ្សែទូរស័ព្ទថ្នាក់ជាតិដោយឥតគិតថ្លៃ រួមជាមួយនឹងការស្រាវជ្រាវ និងឯកសារសម្ភារៈអប់រំផ្សេងៗផងដែរ។
ទូរស័ព្ទ៖ 1800 18 SANE (7263)
វ៉ិបសាយថ៍៖ www.sane.org

**beyondblue: កម្មវិធីផ្តួចផ្តើមថ្នាក់ជាតិអំពីជំងឺធ្លាក់ទឹកចិត្ត**
ព័ត៌មានអំពីការធ្លាក់ទឹកចិត្ត ការថប់បារម្ភ និងវិបល្លាសពាក់ព័ន្ធផ្សេងៗទៀត, វិធីព្យាបាលដែលមាន និងទីកន្លែងរកជំនួយ។
ទូរស័ព្ទ៖ 1300 22 4636
វ៉ិបសាយថ៍៖ www.beyondblue.org.au

**ទាក់ទងអ្នកជំនាញនៅក្នុងតំបន់របស់អ្នក៖**
- វេជ្ជបណ្ឌិតទូទៅ (GP)
- សេវាសុខភាពផ្លូវចិត្ត
- មជ្ឈមណ្ឌលសុខភាពសហគមន៍
- ក្រុមអ្នកជំនាញសុខភាពផ្លូវចិត្តនៅឯមន្ទីរពេទ្យក្នុងតំបន់របស់អ្នក
- មជ្ឈមណ្ឌល/សេវាសុខភាពផ្លូវចិត្តអន្តរវប្បធម៌ (Transcultural Mental Health Centre/Service)

MMHA អាចផ្តល់ជូននូវព័ត៌មានទាក់ទងផ្សេងៗប្រសិនបើមាននៅក្នុងរដ្ឋ ឬដែនដីរបស់អូស្ត្រាលីដែលអ្នកកំពុងរស់នៅ។

### អំពីឯកសារព័ត៌មាននេះ

ឯកសារព័ត៌មាននេះ បានផលិតឡើងដោយស្ថាប័ន **សុខភាពផ្លូវចិត្តពហុវប្បធម៌អូស្ត្រាលី** (MMHA) ដោយបានការឧបត្ថម្ភថវិកាពីក្រសួងកិច្ចការមនុស្សចាស់ជរា និងសុខាភិបាលអូស្ត្រាលី (Australian Department of Health and Ageing)។ ឯកសារព័ត៌មានផ្សេងៗទៀតនៅក្នុងស៊េរីនេះមានរួមទាំង៖
- អ្នកថែទាំជនដែលមានជំងឺផ្លូវចិត្ត
- សិទ្ធិ និងការទទួលខុសត្រូវរបស់អតិថិជនដែលជាអ្នកជំងឺនៅក្នុងប្រព័ន្ធសុខភាពផ្លូវចិត្ត
- អត្តសញ្ញាណវប្បធម៌ និងសុខភាពផ្លូវចិត្ត
- ការស្វែងសុំជំនួយសម្រាប់សុខភាពផ្លូវចិត្តតាមរយៈ វេជ្ជបណ្ឌិត
- ជំងឺបាក់ស្បាត
- ការជាធូរស្បើយពីជំងឺផ្លូវចិត្ត

© April 2011 Multicultural Mental Health Australia

For more information about Multicultural Mental Health Australia
visit www.mmha.org.au
Multicultural Mental Health Australia,
Locked Bag 7118, Parramatta CBD, NSW, 2124
Phone: 02 9840 3333 Fax: 02 9840 3388 Email: admin@mmha.org.au

multicultural MENTAL HEALTH AUSTRALIA